CITY OF LONG BEACH PUBLIC NOTICE

**សេចក្តីជូនដំណឹងជាសាធារណៈ**

ថ្ងៃទី ៣ ខែមិថុនាឆ្នាំ ២០២០

# ទីក្រុងឡុងប៊ិចដាក់បំរាមគោចរទូទាំងក្រុងដែលនឹងចាប់ផ្តើមនៅម៉ោង ៩ ល្ងាចនៅថ្ងៃនេះ

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះទីក្រុងឡុងប៊ិចស្របតាមខោនធី Los Angeles បានដាក់បំរាមគោចរទូទាំងទីក្រុងដែលនឹងចាប់ផ្តើមនៅម៉ោង ៩ ល្ងាចនេះដើម្បីសុវត្ថិភាពសាធារណៈ។ ពេលវេលាអាចត្រូវកែប្រែតាមស្ថានភាពចាំបាច់។

គ្មាននណាម្នាក់នឹងអាចធ្វើដំណើរលើថ្នល់សាធារណៈ វិថីវិថី ផ្លូវច្រក ផ្លូវឧទ្យាន ឬកន្លែងសាធារណៈណាទៀតនៅក្នុងទីក្រុងឡុងប៊ិចបានឡើយក្នុងរយៈពេលនៃបំរាមគោចរនេះលើកលែងតែមានការអនុញ្ញាតច្បាស់លាស់។ ចំពោះបម្រាមគោចរនេះ "ការធ្វើដំណើរ" រួមបញ្ចូលតែមិនកំណត់ចំពោះការធ្វើដំណើរថ្មើរជើង ការជិះកង់ ការជិះក្តារស្គី (skateboard) ការជិះscooter ការជិះម៉ូតូឬរថយន្ត ឬប្រភេទនៃការធ្វើដំណើរផ្សេងទៀត។

រាល់អាជីវកម្មរួមទាំងអាជីវកម្មដែលត្រូវបានចាត់ទុកជា "ចាំបាច់" នៅក្នុងបទបញ្ជាសុខភាពរបស់ទីក្រុងនឹងត្រូវបិទនៅម៉ោង ៩ ល្ងាចថ្ងៃនេះ។

មន្ត្រីអនុវត្តច្បាប់ ក្រុមពន្លត់អគ្គីភ័យ អ្នកផ្តល់សេវាព្យាបាលបន្ទាន់ គ្រូពេទ្យជួយសង្គ្រោះបន្ទាន់ ជនស៊ីវិលដែលចូលរួមក្នុងការងារប៉ូលីសនិងការងារបន្ទាន់ អ្នកដែលត្រូវការការព្យាបាលបន្ទាន់ បុគ្គលដែលធ្វើដំណើរទៅនិងមកពីកន្លែងធ្វើការ អ្នកសារព័ត៌មាន អ្នកដែលកំពុងបិទអាជីវកម្មរបស់គាត់ ប្រជាជនដែលគ្មានផ្ទះសម្បែងនិងគ្មានលទ្ធភាពនឹងទទួលបានទីជំរកដែលអាចរស់នៅបាន និងអ្នកដែលជួយដល់កិច្ច

ប្រឹងប្រែងបោសសំអាតរាល់ការបំផ្លាញដែលបណ្ដាលមកពីសកម្មភាពអស្ថិរភាពស៊ីវិលត្រូវបានលើកលែង។

នៅថ្ងៃទី ៣១ ខែឧសភាឆ្នាំ ២០២០ លោកប្រធានក្រុង Tom Modica ក្នុងនាមជានាយកមន្ទីរការពារស៊ីវិលនៃទីក្រុងឡុងប៊ិចបានប្រកាសភាពអាសន្នក្នុងតំបន់នៅឡុងប៊ិចនិងបានបញ្ជាឱ្យមានបម្រាមគោចរតាមអំណាចដែលមានចែងក្នុងក្រមក្រុង។

នៅថ្ងៃទី ៣០ ខែឧសភាឆ្នាំ ២០២០ ដោយសារសកម្មភាពអស្ថិរភាពស៊ីវិលនិងធនធានក្នុងតំបន់មានកំរិតអភិបាលរដ្ឋ Gavin Newsom បានប្រកាសភាពអាសន្នក្នុងតំបន់សម្រាប់ខោនធី Los Angeles ហើយបានដឹកនាំប្រជាជនទាំងអស់ឱ្យធ្វើតាមដំបូន្មានរបស់មន្ត្រីសង្គ្រោះបន្ទាន់ក្នុងតំបន់។ ច្បាប់ក្រមនៃទីក្រុងឡុងប៊ិចលេខ 2.69 ផ្ដល់សិទ្ធិអំណាចដល់នាយកមន្ទីរការពារស៊ីវិល (ប្រធានគ្រប់គ្រងក្រុង) ឱ្យប្រកាសពីភាពអាសន្នក្នុងតំបន់នៅពេលដែលទីក្រុងត្រូវរងផលប៉ះពាល់ឬទំនងនឹងរងផលប៉ះពាល់ដោយគ្រោះមហន្តរាយឬភាពអាសន្នធំដោយមានការផ្ដល់សច្ចាប័នពីក្រុមប្រឹក្សាក្រុងក្នុងរយៈពេល ៧ ថ្ងៃឬក្នុងករណីដែលក្រុមប្រឹក្សាមិនស្ថិតក្នុងវគ្គប្រជុំ។

ការបិទផ្លូវដែលមានស្រាប់នឹងនៅតែបិទរយៈពេលនៃបំរាមគោចរនេះ។

បំរាមគោចរនឹងមានប្រសិទ្ធិភាពរហូតដល់ម៉ោង ៥ ព្រឹកថ្ងៃទី ៤ ខែមិថុនាឆ្នាំ ២០២០ លើកលែងតែមានការពន្យារពេលប្រសិនបើស្ថានភាពចាំបាច់។

ប្រជាជនអាចទូរស័ព្ទមកលេខ 562.570.INFO (4636) ដើម្បីសុំការបំភ្លឺឬព័ត៌មានបន្ថែម។ បុគ្គលិកនិងម្ចាស់អាជីវកម្មនៅឡុងប៊ិចអាចទូរស័ព្ទមកលេខ 562.570.4BIZ (4249) ប្រសិនបើមានសំណួរ។ ដើម្បីរាយការណ៍អំពីការរំលោភបំពានសូមទូរស័ព្ទមកមន្ទីរប៉ូលីសនៃទីក្រុងឡុងប៊ិចតាមរយៈបណ្ដាញសម្រាប់ករណីដែលមិនមានភាពអាសន្ននៅលេខ 562.435.6711។ សម្រាប់ករណីអាសន្នសូមទូរស័ព្ទទៅលេខ 9-1-1។

ការសាកសួររបស់អ្នកសារព័ត៌មានអាចបញ្ជូនទៅកាន់មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិចនៅលេខ 562.570.NEWS ឬតាមអ៊ីមែលទៅកាន់ jic@longbeach.gov។

# # #